**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ០១ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការទទួលស្គាល់ ការកែប្រែរចនាសម្ព័ន្ធ នៃវិទ្យាស្ថានឯកទេសនៃកម្ពុជា ទៅជា សាកលវិទ្យាល័យឯកទេសនៃកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨.៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មិនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពីការបង្កើត និង ការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និង សិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខណៈវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញអនុក្រឹត្យលេខ ៩១ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០០២ ស្តីពីការទទួលស្គាល់វិទ្យាស្ថានឯកទេសនៃកម្ពុជា
- បានឃើញលិខិតលេខ ៧១១/០៣ វ.ឯ.ក ចុះថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០០៣ របស់វិទ្យាស្ថានឯកទេសនៃកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

# សំរេច

មាត្រា ១ : ទទួលស្គាល់ការកែប្រែចំនោសម្ព័ន្ធ នៃវិទ្យាស្ថានឯកទេសនៃកម្ពុជា ទៅជា សាកលវិទ្យាល័យឯកទេស នៃកម្ពុជា "Cambodian University for Specialties" ហៅកាត់ជាភាសាខ្មែរ "ស.ឯ.ក" និង ហៅកាត់ជាភាសាអង់គ្លេស "C.U.S" ។

សាកលវិទ្យាល័យនេះ មានទីតាំងស្ថិតនៅ :

- អាគារលេខ ៤៣ ផ្លូវ ២៣១ សង្កាត់ផ្សារដើមគរ ខណ្ឌទួលគោក រាជធានីភ្នំពេញ
- អាគារលេខ ៥៨ ផ្លូវ ២៣០ សង្កាត់ផ្សារដើមគរ ខណ្ឌទួលគោក រាជធានីភ្នំពេញ
- អាគារលេខ ១៥ ផ្លូវ ១០៥ សង្កាត់បឹងព្រលឹត ខណ្ឌ ៧ មករា រាជធានីភ្នំពេញ

និង សាខា ៣ កន្លែងស្ថិតនៅ :

- ផ្លូវលោកតាណយ ភូមិបន្ទាយចាស់ ឃុំស្លក្រាម ស្រុកសៀមរាប ខេត្តសៀមរាប
- អតីតសណ្ឋាគាររតនៈ ត្រើយខាងកើតស្ទឹងសង្កែ ទល់មុខសាលាខេត្ត ខេត្តបាត់ដំបង
- អតីតផ្ទះសំណាក់ហាក់លី ភូមិ ៣ ឃុំវាលវង់ ស្រុកកំពង់ចាម ខេត្តកំពង់ចាម ។

មាត្រា ២ : សាកលវិទ្យាល័យឯកទេសនៃកម្ពុជា ស្ថិតនៅក្រោមឱវាទ របស់ក្រសួងអប់រំ យុវជន និងកីឡា ។

មាត្រា ៣ : សាកលវិទ្យាល័យឯកទេសនៃកម្ពុជា ធ្វើការបណ្តុះបណ្តាល :

- ថ្នាក់បរិញ្ញាប័ត្ររង សិក្សារយៈពេលយ៉ាងតិច ២ ឆ្នាំ ។
- ថ្នាក់បរិញ្ញាប័ត្រ សិក្សារយៈពេលយ៉ាងតិច ៤ ឆ្នាំ ។
- ថ្នាក់ម៉ាស្ទ័រ សិក្សារយៈពេលយ៉ាងតិច ២ ឆ្នាំ ។

សាកលវិទ្យាល័យឯកទេសនៃកម្ពុជា ត្រូវរៀបចំ កម្មវិធីសិក្សាលំអិត ដើម្បីសុំការឯកភាពពី ក្រសួងអប់រំ យុវជន និងកីឡា ។

មាត្រា ៤ : សាកលវិទ្យាល័យឯកទេសនៃកម្ពុជា មានមហាវិទ្យាល័យ :

១. មហាវិទ្យាល័យសិល្បៈ មនុស្សសាស្ត្រ និងភាសា

២. មហាវិទ្យាល័យ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា

៣. មហាវិទ្យាល័យ គ្រប់គ្រងពាណិជ្ជកម្ម និងសេដ្ឋកិច្ច

៤. មហាវិទ្យាល័យ វិស្វកម្ម

៥. មហាវិទ្យាល័យវិទ្យាសាស្ត្រសង្គម និងនីតិសាស្ត្រ

ទៅអនាគត សាកលវិទ្យាល័យនេះ អាចបើកមហាវិទ្យាល័យ សាខា ឯកទេស ឬប្រភេទបណ្តុះបណ្តាលផ្សេងទៀត ដោយរៀបចំសំណុំបែបបទសុំការអនុញ្ញាត ពីក្រសួងអប់រំ យុវជន និងកីឡា ។

មាត្រា ៥ : សាកលវិទ្យាល័យឯកទេសនៃកម្ពុជា មានក្រុមប្រឹក្សាភិបាលមួយ សំរាប់ពិនិត្យសំរេច លើគោលនយោបាយ ផែនការអភិវឌ្ឍ និង អនុម័តលើកម្មវិធីសិក្សា និង ការងារបច្ចេកទេសពាក់ព័ន្ធ ។

មាត្រា ៦ : ក្នុងលក្ខខណ្ឌទទួលសិស្សអោយចូលរៀន សាកលវិទ្យាល័យឯកទេសនៃកម្ពុជា ត្រូវគោរពតាមបទដ្ឋាន

របស់ក្រសួងអប់រំ យុវជន និងកីឡា ដែលកំណត់អំពី ការជ្រើសរើស និស្សិតអោយចូលរៀន នៅតាមគ្រឹះស្ថានឧត្តមសិក្សា ។

មាត្រា ៧ : សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យឯកទេសនៃកម្ពុជា មានភារកិច្ច :

- ទទួលខុសត្រូវនៅចំពោះមុខច្បាប់ ក្នុងការគ្រប់គ្រងសាកលវិទ្យាល័យ ។
- ជ្រើសរើសសិស្ស-និស្សិតអោយចូលរៀន សាស្ត្រាចារ្យមកបង្រៀន និងបុគ្គលិកមកបំរើការងារ ។
- គ្រប់គ្រងអោយបានល្អ នូវការងារបណ្តុះបណ្តាល ការងារស្រាវជ្រាវ ការប្រលង និងការប្រគល់សញ្ញាប័ត្រ ។
- គោរព និង អនុវត្តតាម សារាចរ និង សេចក្តីណែនាំ របស់រាជរដ្ឋាភិបាល ។
- ធានាអោយបាន នូវសុវត្ថិភាព និង សណ្តាប់ធ្នាប់សង្គម ។
- ធ្វើរបាយការណ៍ រាល់សកម្មភាពសិក្សា ជូននាយកដ្ឋានឧត្តមសិក្សានៃក្រសួងអប់រំ យុវជន និងកីឡា អោយបានទៀងទាត់ តាមការកំណត់ ។

មាត្រា ៨ : និស្សិត ដែលរៀនចប់កម្មវិធីសិក្សា របស់សាកលវិទ្យាល័យឯកទេសនៃកម្ពុជា និង ទទួលបានជោគជ័យក្នុងការប្រលងបញ្ចប់ការសិក្សា ត្រូវទទួលសញ្ញាប័ត្រ តាមកំរិត និង តាមឯកទេស ដែលបានសិក្សា ។ សញ្ញាប័ត្រនេះ ផ្តល់អោយដោយ សាកលវិទ្យាល័យឯកទេសនៃកម្ពុជា ហើយត្រូវបានទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា ក្នុងករណី សាកលវិទ្យាល័យនេះ បំពេញនិងអនុវត្តបាន តាមគោលការណ៍កំណត់ របស់ក្រសួងអប់រំ យុវជន និងកីឡា ។

មាត្រា ៩ : រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ១០ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា អគ្គនាយកដ្ឋានអង្គភាពពាក់ព័ន្ធ និង សាកលវិទ្យាល័យឯកទេសនៃកម្ពុជា មានភារកិច្ចរៀងៗខ្លួន ដើម្បីអនុវត្ត និង ប្រតិបត្តិតាមអនុក្រឹត្យនេះ ។

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែ មករា ឆ្នាំ ២០០៤

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- សាលាក្រុងភ្នំពេញ
- សាលាខេត្តសៀមរាប
- សាលាខេត្តបាត់ដំបង
- សាលាខេត្តកំពង់ចាម

" ដើម្បីជ្រាប "

- ដូចមាត្រា ១០ " ដើម្បីអនុវត្ត "
- ឯកសារ-កាលប្បវត្តិ